អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥

# សេចក្តីប្រកាសព័ត៌មាន

## ការបញ្ចប់កិច្ចប្រជុំពេញអង្គលើកទី១១

កិច្ចប្រជុំពេញអង្គលើកទី១១ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបញ្ចប់កាលពីរសៀលនេះ បន្ទាប់ពីបានកោះប្រជុំជាថ្មី ក្រោយពេលឈប់សម្រាកសវនាការនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤។

កិច្ចប្រជុំពេញអង្គបានអនុម័តបទប្បញ្ញត្តិថ្មីៗដែលនឹងអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេត ធ្វើការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ដោយដកចេញនូវអង្គហេតុមួយចំនួនដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមណាមួយ នៅពេលជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត ដរាបណាអង្គហេតុដែលនៅសេសសល់តំណាងឲ្យវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមណាមួយ។

ស្រដៀងគ្នាដែរ វិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិនានាដែលនឹងអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ ដោយដកចេញនូវអង្គហេតុមួយចំនួនដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដរាបណាអង្គហេតុនៅសេសសល់ដែលត្រូវយកមកជំនុំជម្រះ តំណាងឲ្យវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សេចក្តីសម្រេចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះនឹងមិនប៉ះពាល់ដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសមាសភាពក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូលគ្នាតែមួយនោះទេ។

វិធានពាក់ព័ន្ធនឹងអង្គភាពគាំពារជនរងគ្រោះ (VSS) ត្រូវបានធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិនានា ដែលគ្រប់គ្រងលក្ខណៈវិនិច្ឆ័យ ដែលនឹងដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះមេធាវីតំណាងដើមបណ្តឹងរដ្ឋ

ប្បវេណីនៅចំពោះមុខ អ.វ.ត.ក និងតួនាទីរបស់អង្គភាពគាំពារជនរងគ្រោះ ក្នុងការបញ្ជូនពាក្យសុំរបស់មេធាវីបរទេស ដែលមានបំណងធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដាក់ជូនទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការធ្វើវិសោធនកម្មទាំងនេះត្រូវបានអនុម័ត ក្នុងគោលបំណងពន្លឿនកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក Lars Olsen**
មន្ត្រីច្បាប់
ទូរស័ព្ទដៃ៖ +៨៥៥(០)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុ៖ +៨៥៥(០)២៣ ៨៦១ ៦៦៩
អ៊ីមែល៖ olsen@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីអ្នកនាំពាក្យ
ទូរស័ព្ទដៃ៖ +៨៥៥ (០) ១២ ៤៨៨ ១៤៦
អ៊ីមែល៖ neth.phektra@eccc.gov.kh



Original EN: 01699216-01699216